# ១៣ - រឿង បុរសពីរនាក់ចង់បានប្រពន្ធគេ



Top-Tablets bei o2
jetzt online bei o2 bestellen.
Exklusive Tablets für einmalig 1€.

មានរឿងមួយថា មានបុរសម្នាក់ មានប្រពន្ធល្អ ទើបតែរៀបការថ្មីៗ បណ្តើរគ្នាទៅសួរញាតិ មានកម្លោះពីរនាក់ បានឃើញ ក៏ស្រឡាញ់ចង់បាន វាគិតថា «យើងធ្វើដូចម្តេចនឹងបានអេះ ? »។ ចៅម្នាក់ ឆ្លើយថា «ងាយទេ ឯងគិតទៅរកខ្ទីរទេះគោមកបរ ប៉ុន្តែឯងមិនស្គាល់អញ បើអញសួរឯងៗ កុំប្រាប់ថារទេះ ចូរឯងប្រាប់ថាចន្ទោល ថានឹមទៅវិញ »។ ទើបកម្លោះម្នាក់ទៅខ្ចីរទេះគេមកបរឲ្យជួបនឹងបុរសបណ្តើរប្រពន្ធនោះដើរមកដល់, ក៏កម្លោះម្នាក់នោះវាសួរថា «នែអ្នក ! អញ្ជើញមកអាយ ឈប់និយាយគ្នាលេងបន្តិចសិន » ។ បុរសការប្រពន្ធថ្មី ក៏ចូលទៅអង្គុយលេង ។ លុះកម្លោះម្នាក់បររទេះមកដល់វាធ្វើជាសួរថា « នេះហៅអ្វីអ្នក?»។ បុរសប្តីប្រពន្ធ ឆ្លើយប្រាប់ថា « គេហៅរទេះ»។ មែនឬអ្នក ? បុរសនោះថា មែន ។ «បើមែនអ្នកហ៊ានភ្នាល់នឹងខ្ញុំទេ»។បុរសនោះសួរថា «អ្នកឯងមានទ្រព្យអ្វីភ្នាល់នឹងយើង ? ។ កម្លោះនោះថា បើខ្ញុំចាញ់ ខ្ញុំនៅជាខ្ញុំអ្នក បើខ្ញុំឈ្នះសុំតែប្រពន្ធអ្នក ។ បុរសនោះគិតថា ប្រាកដជាគេហៅរទេះមែននឹងខ្លាចអ្វី ក៏ព្រមភ្នាល់នឹងគេទៅ ។ ទើបកម្លោះដែលឈរ សួរទៅអ្នកបររទេះចង្អុលទៅសួរទៅចន្ទោល, កម្លោះអ្នកបររទេះប្រាប់ថានេះគេហៅចន្ទោល។ ចង្អុលសួរទៅនឹមថា នេះគេហៅនឹម ។ «នេះគេហៅទូក ,នេះគេហៅទ្រាយ,នេះគេហៅប្រែក, នេះគេហៅកង់, នេះគេហៅខ្នងកង់, នេះគេហៅត្រពង។ ដល់ឆ្លើយរួចសព្វគ្រប់ កម្លោះនោះសួរទៅបុរសជាប្តីថា ឥឡូវ គេមិនហៅរទេះទេ បើដូច្នោះតើអ្នកឯងព្រមចាញ់យើងឲ្យប្រពន្ធមកយើងឬម្តេច ? បុរសជាប្តីនោះមិនព្រម, ដល់ប្រកែកទៅមិនឈ្នះគេៗ ដណ្តើមយកប្រពន្ធទៅបាន ។ បុរសនោះមិនសុខចិត្តទៅប្តឹងចៅក្រមៗ ឲ្យទៅកោះចៅទាំងពីរនោះមកជំនុំ, កម្លោះទាំងពីរនាក់នោះវាសូកចៅក្រមៗកាត់សេចក្តីថា ត្រូវចាញ់គេហើយ ត្រូវឲ្យប្រពន្ធទៅគេហើយ ។ បុរសនោះខឹងណាស់ ត្បិតគេយកប្រពន្ធទៅបាន ដើរផង យំផង, ដើរបន្តិចទៅប្រទះសុភាទន្សាយៗសួរថា ថ្វីបានជាយំបង ? ។ បុរសនោះប្រាប់តាមដំណើរសព្វគ្រប់ ។ សុភាទន្សាយថា បើដូច្នោះបងឯងកុំភ័យ រកតែចេកមកឲ្យយើងស៊ីសិន យើងទៅជួយជំនុំឲ្យបានប្រពន្ធមកវិញ ។ បុរសនោះអរណាស់ ខំទៅរកចេកមកឲ្យសុភាទន្សាយៗ ស៊ីចេករួចហើយ ដើរទៅជាមួយបុរសនោះ ទៅដល់សួរចៅក្រមថា លោកកាត់សេចក្តីគេនោះ តើដូចម្តេចខ្លះ ? ។ ចៅក្រម ឆ្លើយប្រាប់តាមដំណើរសព្វគ្រប់ ។ សុភាទន្សាយថា លោកកាត់សេចក្តី មិនទាន់អស់ទេ បើដូច្នេះខ្ញុំសូមកាត់សេចក្តីនេះផង ឲ្យសុខចិត្តទាំងពីរខាង។ សុភាទន្សាយ សួរកម្លោះដែលយកប្រពន្ធគេមកនោះថា អ្នកទាំងពីរនាក់កាលភ្នាល់គ្នាថាដាក់អ្វី ? ។ បុរសនោះឆ្លើយថា ដាក់ប្រពន្ធ ។ សុភាទន្សាយ សួរទៅកម្លោះនោះថា ត្រង់ណាហៅប្រពន្ធ បើអ្នករកឃើញយកទៅចុះ បើរកមិនឃើញទេ ឲ្យប្រពន្ធទៅគេវិញទៅ។ កម្លោះនោះចាប់ត្រង់ដៃ, សុភាទន្សាយប្រាប់ថា នេះគេហៅថាដៃទេ វាចាប់ត្រង់ជើង សុភាទន្សាយថា នេះគេហៅជើងទេ វាចាប់ត្រង់នេះ ក៏ថាមិនមែន, ត្រង់នោះក៏ថាមិនមែន ហើយប្រាប់ថារួមទាំងអស់គ្នាទៅទើបគេហៅ« ប្រពន្ធ » ឯរទេះក៏ដូចគ្នាគឺគេហៅចន្ទោល នឹម ទូក ទ្រាយ ប្រែក ធ្នង់ ត្រពង រួមទាំងអស់នេះទៅ ទើបហៅថា« រទេះ» បើដូច្នេះ ឯងយកប្រពន្ធគេ មិនបានទេ ឲ្យមកគេវិញ ។ សុភាទន្សាយឲ្យកម្លោះនោះ យកប្រពន្ធមកវិញ។ សុភាទន្សាយស្តីឲ្យលោកចៅក្រមថា បងកាត់សេចក្តីនេះស៊ីតែសំណូកគេ គ្មានត្រង់តាមព្រះច្បាប់សោះ។ បុរសនោះប្រាប់ប្រពន្ធមកវិញ ក៏អរណាស់ លើកដៃសំពះសុភាទន្សាយថា លោកបងកាត់សេចក្តីនេះ ពេញហៅត្រង់ហើយ ឲ្យលោកបានសម្បត្តិសួគ៌និព្វាន ។

**ប្រាជ្ញឯង ឲ្យក្រែងប្រាជ្ញគេ**

g+1 +2 Recommend this on Google


# Top-Tablets bei o2

Exklusive Tablets mit o2 Go Flat. Jetzt günstig mobil bei o2 sichern.


ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអ៊ីមែលក្នុងប្រអប់នេះ

Email address... ចង់បាន

នាំមកជូនលោកអ្នកដោយ


